ក្រសួងអប់រំរដ្ឋ NSW

# ការអប់រំដែលមានសក្តានុពលខ្ពស់ និងមានទេពកោសល្យ នៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW - ការណែនាំសម្រាប់ឪពុកម្តាយ និងអ្នកថែទាំ

ការអប់រំដែលមានសក្តានុពលខ្ពស់ និងមានទេពកោសល្យ (High Potential and Gifted Education (HPGE)) ជួយសិស្សទាំងអស់នៅសាលារៀនរដ្ឋក្នុងរដ្ឋ NSW ឱ្យរក្សាចំណាប់អារម្មណ៍ និងប្រឈមក្នុងការសិក្សារបស់ពួកគេ ដោយបំពេញតម្រូវការសិក្សាជាក់លាក់របស់ពួកគេ។ វាផ្តោតលើវិស័យ (ប្រភេទ) នៃសក្តានុពល 4៖ ភាពច្នៃប្រឌិត បញ្ញា រាងកាយ និងសង្គម-អារម្មណ៍។

## វិស័យនៃសក្តានុពលទាំង 4

វិស័យនៃសក្តានុពលគឺ 4 ប្រភេទសំខាន់ៗនៃសមត្ថភាពពីកំណើតដែលមនុស្សអាចមាន។ វិស័យទាំងនេះច្រើនតែទាក់ទងត្រួតលើគ្នា ហើយមានឥទ្ធិពលពីគ្នាទៅវិញទៅមកយ៉ាងខ្លាំង។ ខាងក្រោមគឺជាវិស័យទាំងនេះ៖

**វិស័យច្នៃប្រឌិត** - សំដៅទៅលើសមត្ថភាពនានាដែលប្រើការស្រមើលស្រមៃ ភាពដើម និងការមានគំនិតថ្មីៗ។ សមត្ថភាពទាំងនេះអាចត្រូវបានគេមើលឃើញនៅក្នុងកុមារតាមរយៈវិធីដែលពួកគេសរសេររឿងខ្លីមួយ និពន្ធបទចម្រៀង គូរផ្ទាំងរូបភាព បង្កើតដំណោះស្រាយដែលមានលក្ខណៈប្លែកពិសេសចំពោះទៅនឹងចំណោទគណិតវិទ្យា ឬការតែង ឬក្បាច់រាំ។

**វិស័យបញ្ញា** - សំដៅទៅលើសមត្ថភាពនានាក្នុងការយល់ដឹងអំពីគំនិតស្មុគស្មាញ ការដោះស្រាយបញ្ហា និងការអនុវត្តន៍ចំណេះដឹង។ ជាឧទាហរណ៍ កុមារអាចរៀនបានយ៉ាងឆាប់រហ័ស និងងាយស្រួល ឬបង្ហាញការយល់ដឹងយ៉ាងស៊ីជម្រៅអំពីទស្សនវិជ្ជា វិទ្យាសាស្ត្រ ឬសៀវភៅ។

**វិស័យរាងកាយ** - សំដៅទៅលើសមត្ថភាពធម្មជាតិនានាក្នុងចលនារបស់មនុស្ស។ ជាឧទាហរណ៍ ក្នុងអំឡុងពេលសកម្មភាពកីឡា ការកាត់ដេរ កិច្ចការជាងឈើ ឬវិស្វកម្ម។ សមត្ថភាពទាំងនេះអាចត្រូវបានគេកត់សម្គាល់ឃើញនៅក្នុងថ្នាក់រៀន និងសួនកុមារ ក៏ដូចជាតាមរយៈសកម្មភាពក្រៅកម្មវិធីសិក្សានៅសាលា និងឱកាស និងការប្រកួតប្រជែងក្នុងសហគមន៍។

**វិស័យសង្គម-អារម្មណ៍** - សំដៅទៅលើសមត្ថភាពនានាក្នុងការគ្រប់គ្រងអារម្មណ៍របស់ពួកគេ និងការទំនាក់ទំនងជាមួយអ្នកដទៃ។ សមត្ថភាពទាំងនេះអាចត្រូវបានបង្ហាញតាមរយៈការប្រាស្រ័យទាក់ទងជាមួយមិត្តរួមថ្នាក់ គ្រូបង្រៀន និងឪពុកម្តាយ ឬអ្នកថែទាំ។ ជាឧទាហរណ៍ កុមារអាចមានទំនុកចិត្ត និងពូកែខ្លាំងក្នុងការដឹកនាំ និងធ្វើការជាមួយអ្នកដទៃ ឬបង្ហាញជំនាញសហគ្រិន។

## របៀបដែលសាលារៀនគាំទ្រសិស្សដែលមានសក្តានុពលខ្ពស់ និងមានទេពកោសល្យ

សក្តានុពលរបស់កុមារអាចប្រែប្រួល ដូច្នេះពួកគេអាចត្រូវការជំនួយ និងការបង្រៀនផ្សេងៗគ្នា។ ជាឧទាហរណ៍៖

**សិស្សដែលមានសក្តានុពលខ្ពស់** គឺជាសិស្សដែលមានសមត្ថភាពខ្ពស់ជាងសិស្សដែលមានអាយុដូចគ្នា ហើយពួកគេអាចទទួលបានអត្ថប្រយោជន៍ពីការដាក់ឱ្យប្រឈមកាន់តែច្រើន។

**សិស្សដែលមានទេពកោសល្យ** មានសមត្ថភាពខ្ពស់ខ្លាំង បើប្រៀបធៀបទៅនឹងសិស្សដែលមានអាយុដូចគ្នា ហើយអាចអភិវឌ្ឍទេពកោសល្យរបស់ពួកគេបានយ៉ាងឆាប់រហ័ស និងងាយស្រួលនៅពេលផ្តល់ឱកាស។

**សិស្សដែលមានទេពកោសល្យខ្ពស់** មានសមត្ថភាពពិសេស ហើយអាចត្រូវការការកែសម្រួលសំខាន់ៗ ដើម្បីបំពេញតម្រូវការសិក្សាកម្រិតខ្ពស់របស់ពួកគេ។

សាលារៀនគាំទ្រសិស្សដែលមានសក្តានុពលខ្ពស់ និងមានទេពកោសល្យតាមរយៈការអនុវត្តន៍ និងកម្មវិធីបង្រៀនផ្សេងៗ។ ទាំងនេះអាចរួមបញ្ចូល៖

- មេរៀននានាដែលប្រឈម និងជំរុញទឹកចិត្តសិស្ស
- សកម្មភាពកែលម្អ និងសកម្មភាពក្រៅកម្មវិធីសិក្សា
- ការដាក់សិស្សជាក្រុមជាមួយសិស្សដែលមានសមត្ថភាពស្រដៀងគ្នា
- ផ្លូវសិក្សាកម្រិតខ្ពស់ដូចជាការពន្លឿន (ការផ្លាស់ប្តូរតាមរយៈកម្មវិធីសិក្សាកាន់តែលឿន) នៅពេលសមស្រប
- គាំទ្រដល់សុខុមាលភាព និងការអភិវឌ្ឍន៍ជំនាញសង្គម។

គោលដៅគឺដើម្បីជួយសិស្សផ្លាស់ប្តូរពីសក្តានុពលខ្ពស់ ទៅការអនុវត្តន៍ខ្ពស់ - ទោះថានៅក្នុងផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ភាសា សិល្បៈ កីឡា ភាពជាអ្នកដឹកនាំ ឬផ្នែកផ្សេងទៀត។

## សិស្សម្នាក់ៗមានលក្ខណៈប្លែកពិសេស

សិស្សដែលមានសក្តានុពលខ្ពស់អាចមកពីប្រវត្តិណាមួយ រួមទាំងពិការភាព ឬមកពីប្រវត្តិ និងក្រុមភាសាផ្សេងៗគ្នា។ សិស្សខ្លះធ្វើបានយ៉ាងល្អនៅសាលារៀនរួចហើយ ខណៈដែលសិស្សខ្លះទៀតប្រហែលជាត្រូវការជំនួយបន្ថែមដើម្បីធ្វើឱ្យអស់ពីសមត្ថភាពរបស់ពួកគេ។ វាជាការយល់ខុសជាទូទៅដែលថា សិស្សដែលមានទេពកោសល្យមិនត្រូវការការគាំទ្រទេ ពីព្រោះអ្នកខ្លះអាចត្រូវការជំនួយជាក់លាក់ដើម្បីរក្សាចំណាប់អារម្មណ៍ និងធ្វើបានល្អនៅសាលារៀន។

## អ្វីដែលត្រូវធ្វើប្រសិនបើអ្នកជឿជាក់ថាកូនរបស់អ្នកមានសក្តានុពលខ្ពស់ ឬអាចមានទេពកោសល្យ

ប្រសិនបើអ្នកគិតថាកូនរបស់អ្នកអាចមានសក្តានុពលខ្ពស់ ឬអាចមានទេពកោសល្យ សូមពិភាក្សារឿងនេះជាមួយគ្រូបង្រៀនរបស់កូនអ្នក។ នៅពេលអ្នកនិយាយជាមួយគ្រូបង្រៀន សូមផ្តល់ឧទាហរណ៍នានាអំពីអ្វីដែលកូនរបស់អ្នកធ្វើ ដែលអាចជាសញ្ញានៃសក្តានុពលខ្ពស់ ឬមានទេពកោសល្យនៅក្នុងវិស័យណាមួយ។

ឪពុកម្តាយ និងអ្នកថែទាំដើរតួនាទីយ៉ាងសំខាន់ដោយទាក់ទិនក្នុងការសិក្សារបស់កូនពួកគេ ការចែករំលែកការយល់ដឹងអំពីកូនរបស់ពួកគេ និងធ្វើការជាដៃគូជាមួយសាលារៀន។

## គោលនយោបាយ HPGE

គោលនយោបាយអប់រំដែលមានសក្តានុពលខ្ពស់ និងមានទេពកោសល្យ ត្រូវបានប្រើនៅគ្រប់សាលារៀនរដ្ឋនៅទូទាំងរដ្ឋ NSW។ វាជួយគ្រូបង្រៀនវាយតម្លៃ និងកំណត់នូវអ្វីដែលសិស្សមានសក្តានុពលខ្ពស់ និងមានទេពកោសល្យត្រូវការ និងរបៀបផ្តល់ឱកាសឱ្យពួកគេរីកចម្រើន និងជោគជ័យ។

## កន្លែងទទួលបានព័ត៌មានបន្ថែម

- គ្រប់សាលារៀនរដ្ឋក្នុងរដ្ឋ NSW ផ្តល់ជូនសកម្មភាព HPGE។ សូមមើលគេហទំព័រសាលារៀនរបស់កូនអ្នកសម្រាប់ព័ត៌មានលម្អិតបន្ថែម។
- អ្នកប្រហែលជាចង់និយាយជាមួយគ្រូបង្រៀនរបស់កូនអ្នក ដើម្បីសួរពីរបៀបដែលសាលារៀនគាំទ្រអ្នកសិក្សាដែលមានសក្តានុពលខ្ពស់ និងមានទេពកោសល្យ។
- សូមចូលមើលគេហទំព័រការអប់រំដែលមានសក្តានុពលខ្ពស់ និងមានទេពកោសល្យរបស់ក្រសួង ដើម្បីស្វែងរកគោលនយោបាយ និងធនធាននានា។

## សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកត្រូវការជំនួយអ្នកបកប្រែផ្ទាល់មាត់ ដើម្បីនិយាយទៅកាន់សាលារៀនរបស់កូនអ្នកអំពីការអប់រំដែលមានសក្តានុពលខ្ពស់ និងមានទេពកោសល្យ សូមទូរសព្ទទៅលេខ 131 450។ សូមប្រាប់ការីទូរសព្ទនូវភាសាដែលអ្នកត្រូវការ ហើយស្នើសុំឱ្យពួកគេទូរសព្ទទៅសាលារៀន។

ការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់ម្នាក់តាមទូរសព្ទ ដើម្បីជួយក្នុងការសន្ទនារបស់អ្នក។ គេនឹងមិនគិតថ្លៃសេវានេះពីអ្នកទេ។